**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបុណ្យព្រះនាងម៉ារីគ្មានជំពាក់បាបនៅភ្នំពេញថ្មី**
**ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧**
*ក្រុមគ្រួសារជាព្រះសហគមន៍ដំបូង*

| |
|---|
| អត្ថបទទី១៖ កណ ៣,៩-១៥.២០<br>អត្ថបទទី២៖ អភ ១,៣-៦.១១-១២<br>ដំណឹងល្អ៖ លក ១,២៦-៣៨ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមានអំណរសប្បាយរួមគ្នាជាមួយព្រះនាងម៉ារី ដែលយើងគោរពព្រះនាងម៉ារីគ្មានជំពាក់បាប។ ថ្ងៃនេះយើងមានអំណរសប្បាយ ដោយសារយើងទទួលបុត្រធីតារបស់ព្រះជាម្ចាស់បីនាក់ថ្មី។ ខ្ញុំនឹកឃើញដល់ឪពុកម្តាយរបស់ព្រះនាងម៉ារី លោកតាយ៉ូហានគីម និងលោកយាយហា គេបានថែរក្សាកូនរបស់ពួកគេ។ ប៉ុន្មានអាទិត្យមុនយើងបានធ្វើពិធីមួយ គឺលោកតាយ៉ូហានគីម និងលោកយាយហាណា បានថ្វាយព្រះនាងម៉ារីទៅវិហារយេរូសាឡឹម។ ហើយនៅពេលនោះនាងម៉ារីអាយុតែ៣ឆ្នាំ និងគេទុកព្រះនាងម៉ារីដែលជាកូនតូចតាចពីអាយុ៣ឆ្នាំរហូតដល់ប្រហែលអាយុ១១ឆ្នាំ។ អាយុ៧ឆ្នាំនាងម៉ារី តាមពិតនៅវិហារក្រុងយេសរូសាឡឹម ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីរៀបចំខ្លួនឲ្យស្គាល់របៀបអធិដ្ឋាន ឲ្យស្គាល់ជីវិតនៅក្នុងវិសាលវិហារនេះ។ ពេលត្រលប់មកវិញ អាយុ១១ឆ្នាំដល់ផ្ទះ ក្រោយមកនៅអាយុ១៥ឆ្នាំ បានទទួលដំណឹងល្អពីទេវទូតកាព្រីអែល ធ្វើជាមាតារបស់ព្រះជាម្ចាស់។ ព្រះនាងម៉ារីឆ្លើយបាន ដោយសារបានរៀបចំខ្លួនរួចហើយ មូលហេតុដែលរៀបចំខ្លួនរួចហើយ ដោយសារឪពុកម្តាយ។

ដូច្នេះថ្ងៃនេះ ជាឱកាសមួយដើម្បីនឹកឃើញដល់តួនាទីឪពុកម្តាយ យើងមានយុវនារីច្រើនណាស់ និងអនាគតយើងចង់រៀបការដែរសូមឲ្យគិតសិន។ និយាយទៅកាន់បងស្រីដើម្បីឲ្យបងស្រីគិតទៅដើម្បីអប់រំយុវនារីផង ធ្វើយ៉ាងម៉េចដើម្បីរៀបចំខ្លួនទៅថ្ងៃអនាគតក្នុងការធ្វើជាឪពុកម្តាយយ៉ាងល្អ។ នៅថ្ងៃនេះខ្ញុំចង់យកគំរូខ្លះៗ ចេញពីឪពុកម្តាយសន្តីតេរេសា។ សន្តីតេរេសា ជាសន្តីរបស់យើងដែលនរណាក៏ស្រឡាញ់ ឪពុកម្តាយក៏ជាសន្តសន្តីដែរ។ នេះជាគ្រួសារដ៏វិសុទ្ធម្យ៉ាង ដែលព្រះសហគមន៍បានតែងតាំងឪពុកម្តាយរបស់សន្តីតេរេសានៃព្រះកុមារយេស៊ូឲ្យទៅជាសន្តសន្តីដែរដើម្បីយកជាគំរូ។ មានអត្ថបទខ្លះៗ ដែលឪពុកម្តាយរបស់សន្តីតេរេសា បានសរសេរទុកជាអនុស្សាវរីយ៍ទាក់ទងនឹងជីវិតរបស់គេ។ មាន

ឃ្លាមួយចេញពីម្ដាយរបស់បងស្រីតេរេសា។ ឪពុកម្ដាយ (ល្វីស និងសេរីម៉ាតាំង) មានកូនស្រី៥នាក់ និងម្ដាយបាននិយាយដូចនេះថា "**ខ្ញុំអប់រំ ចិញ្ចឹម ណែនាំកូនរបស់ខ្ញុំ ដើម្បីឲ្យពួកគេទៅស្ថានបរមសុខ ដូច្នេះការសិក្សាដែលខ្ញុំណែនាំកូន ស្រឡាញ់កូនខ្ញុំ ថែរក្សាកូនខ្ញុំ ខ្ញុំធ្វើយ៉ាងម៉េចដើម្បីឲ្យកូនខ្ញុំទៅថ្ងៃអនាគត ទៅជាសន្តសន្តីដ៏ពិសេស ដើម្បីមានកន្លែងល្អអស្ចារ្យនៅស្ថានបរមសុខ**"។ ឪពុកម្ដាយសន្តីតេរេសា និងកូនគេទាំង៥នាក់ គេបានយកចិត្តទុកដាក់អស់មួយជីវិត និងជាពិសេសគេបានយកចិត្តទុកដាក់ទីមួយ មុនចូលគេង បានអធិដ្ឋានរាល់ថ្ងៃ។ អធិដ្ឋានតិចៗ បពិត្រព្រះនាងម៉ារី ឱព្រះបិតាអើយ! ដើម្បីឲ្យកូនចូលនៅក្នុងជីវិតព្រះជាម្ចាស់បន្តិចម្ដងៗ។

នៅពេលឪពុកម្ដាយជួយបំបាក់អារ ពេលនោះឪពុកម្ដាយនិយាយ "**យើងជូនដួងចិត្តបេះដូងរបស់យើង ទៅព្រះជាម្ចាស់ដែលស្រឡាញ់យើងយ៉ាងខ្លាំង**"។ ដូច្នេះ ពេលព្រឹកឡើងពេលឪពុកម្ដាយជួយបំពាក់អារ ស្លៀកខោដល់កូនគេ និយាយដូច្នេះ "**យើងជូនមួយថ្ងៃនៃបេះដូងរបស់យើង អំណរសប្បាយរបស់យើង ទុក្ខលំបាករបស់យើង ទៅព្រះជាម្ចាស់ទៅ**" ដោយសារព្រះជាម្ចាស់ស្រឡាញ់យើង។ សំខាន់ណែនាំកូនៗ ព្រឹកឡើងជម្រាបសួរទៅព្រះជាម្ចាស់ ព្រឹកឡើងពាក្យទីមួយ ជម្រាបសួរព្រះយេស៊ូ ជម្រាបសួរព្រះនាងម៉ារី...។ ឪពុកម្ដាយនិយាយថា "**ថ្ងៃនេះជាថ្ងៃពិសេស ដែលយើងមានអំណរសប្បាយរួមគ្នា ហើយយើងដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង**"។ យើងជឿថា ព្រះនាងម៉ារីអាចឆ្លើយទៅព្រះជាម្ចាស់យ៉ាងស្រួល និងព្រះនាងម៉ារីបានទទួលភាពដ៏វិសុទ្ធដ៏អស្ចារ្យ ដោយសារព្រះនាងម៉ារីរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ ដូចជាព្រះជាម្ចាស់រស់នៅជាមួយគាត់រហូត។ គាត់នឹកឃើញ ព្រះជាម្ចាស់នៅទីនេះ ការពារគាត់ ពេលគាត់ពិបាកមួយថ្ងៃៗ។ យើងត្រូវការណែនាំឲ្យកូនរបស់យើង រស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់យ៉ាងច្បាស់។ រាល់ថ្ងៃអាទិត្យ ឪពុកម្ដាយសន្តីតេរេសា គេជូនកូនដោយធ្វើដំណើរពីផ្ទះដើម្បីចូលព្រះវិហារ។

យើងណែនាំរៀងរាល់អាទិត្យ ឲ្យកូនយើងចូលព្រះវិហារ ដើម្បីស្រឡាញ់ព្រះជាម្ចាស់ តាំងពីខ្ញុំនៅក្មេង ឪពុកម្ដាយរបស់ខ្ញុំរាល់ថ្ងៃអាទិត្យចាប់ដៃខ្ញុំទៅព្រះវិហា រអត់ដែលខានទេ។ ឪពុកម្ដាយកុំភ្លេច ធ្វើយ៉ាងម៉េចដើម្បីណែនាំកូនយើងចូលក្នុងព្រះវិហាររៀងរាល់អាទិត្យ ដើម្បីស្គាល់ព្រះជាម្ចាស់ ដើម្បីចូលនៅក្នុងបរិយាកាសពិសេស ជាមួយព្រះជាម្ចាស់ជាមួយគ្រីស្តបរិស័ទ បទចម្រៀងដែលគេស្ដាប់។ ពេលគេស្ដាប់បទចម្រៀងពីក្មេង គេចូល

អស់មួយជីវិត ជួនកាលពេលគេមានអាយុ១៨ឆ្នាំ ១៩ឆ្នាំ ចង់ធ្វើតាមចិត្ត ជួនកាលគេទៅឆ្ងាយពីព្រះសហគមន៍ ទៅឆ្ងាយពីពុកម្ដាយ។ ក្រោយមកគេត្រលប់មកវិញ ដោយសរបានទទួលអ្វីៗទាំងអស់ពីឪពុកម្ដាយតាំងពីដើរៀងមក និងព្រះសហគមន៍ដែលជាគ្រួសារមួយយ៉ាងពិសេស។

ដូច្នេះថ្ងៃនេះ ពិតមែនយើងអរព្រះគុណព្រះជាម្ចាស់ យើងសូមព្រះអង្គជួយយើងជាព្រះសហគមន៍ទាំងមូល ដើម្បីបង្កើតបរិយាកាសជាក្រុមគ្រួសារតែមួយ។ ដោយសារយើងមិនមែនមានតែឪពុកម្ដាយទេ ប៉ុន្តែបងប្អូនទាំងអស់ទៅជាក្រុមគ្រួសាររបស់យើង។ នៅពេលយើងចូលព្រះវិហារម្ដងៗជាឱកាសមួយ ដើម្បីសួរសុខទុក្ខគ្នាទៅវិញទៅមក សួរសុខទុក្ខព្រះជាម្ចាស់ និងជាពិសេសនៅក្នុងរដូវរង់ចាំនេះ ជាពេលវេលាមួយដើម្បីទន្ទឹងរង់ចាំរៀបចំខ្លួន ដោយសារជាពេលវេលាដែលព្រះជាម្ចាស់យាងមក ដើម្បីសួរសុខទុក្ខយើង។ មិនមែនយើងទៅសួរសុខទុក្ខព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់យាងមកសួរសុខទុក្ខយើង និងដើម្បីធ្វើដំណើរជាមួយយើង។

អនាគត នៅពេលដែលយើងក្លាយជាឪពុកម្ដាយកុំភ្លេច ធ្វើយ៉ាងម៉េចដើម្បីឲ្យផ្ទះរបស់យើង គ្រួសាររបស់យើងទៅជាព្រះសហគមន៍ដ៏តូចមួយ។ ព្រះសហគមន៍ដំបូងបំផុតគឺឪពុកម្ដាយ លោកតា លោកយាយ ជាមួយកូនចៅ ដើម្បីធ្វើយ៉ាងម៉េចក្លាយទៅជាព្រះសហគមន៍ដ៏តូចមួយ ដែលចេះស្រឡាញ់ ថែរក្សា និងលើកលែងទោសជានិច្ច។ យើងអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គជួយបំភ្លឺយើង ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតដែលពោរពេញដោយអំណរសប្បាយ ដូចព្រះនាងម៉ារី ទន្ទឹងរង់ចាំព្រះយេស៊ូដែលកំពុងយាងមក ព្រះសង្គ្រោះដែលយាងមក ដើម្បីណែនាំឲ្យយើងទទួលជីវិតអស់កល្បជានិច្ច ដូចម្ដាយរបស់សន្តីតេរេសាបាននិយាយថា "**ខ្ញុំអប់រំកូន ណែនាំកូន ឲ្យកូនខ្ញុំទទួលជីវិតអស់កល្បជានិច្ចជាមួយព្រះជាម្ចាស់**"។ អាម៉ែន៕